**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ១១៣០ សអិលា

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៤

**ជម្រាបមក**

**ឯកឧត្តមអភិបាល រាជធានីភ្នំពេញ អភិបាលគ្រប់ខេត្ត**
**និងជាប្រធានគណៈកម្មការរៀបចំការប្រឡងរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** : ស្តីពីការពន្យារពេលទទួលពាក្យប្រឡង និងពន្យារពេលប្រឡងជ្រើសរើសបេក្ខជនបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៤ ។

**<u>យោង</u>** : ប្រកាសលេខ ១៥៣៥ ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូនឯកឧត្តមថា កន្លងមកក្រសួងមហាផ្ទៃ បានកំណត់កាលបរិច្ឆេទប្រឡងជ្រើសរើសបេក្ខជនជាសិស្ស និស្សិត ឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៤ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៤ និងកំណត់កាលបច្ឆេទទទួលពាក្យប្រឡងត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ។

ដោយពិនិត្យឃើញថា ក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត កំពុងមមាញឹកក្នុងការរៀបចំដំណើរការប្រកាសចូលតំណែងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី ២ នៅទូទាំងប្រទេស និងផ្អែកតាមស្ថានភាពបេក្ខជនជាសិស្ស និស្សិត ដែលបានមកដាក់ពាក្យប្រឡងនៅមានចំនួនមិនទាន់សមស្របសម្រាប់ដំណើរការរៀបចំការប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីតាមកាលបរិច្ឆេទកំណត់ខាងលើ ក្រសួងមហាផ្ទៃ សម្រេចពន្យារកាលបរិច្ឆេទ នៃការប្រឡង ដូចខាងក្រោម ៖

១- កាលបរិច្ឆេទនៃការទទួលពាក្យប្រឡង ត្រូវពន្យារពេលពីថ្ងៃសុក្រទី៣០ ខែឧសភា ឆ្នាំ២០១៤ រហូតដល់ថ្ងៃសុក្រ **ទី២៧ ខែមិថុនា ឆ្នាំ២០១៤** ។

២- កាលបរិច្ឆេទនៃការប្រឡង ដែលកំណត់កាលបរិច្ឆេទនៅថ្ងៃអាទិត្យ ទី២៩ ខែមិថុនា ឆ្នាំ២០១៤ ត្រូវពន្យារពេល **ទៅថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០១៤ ខាងមុខវិញ** ។

ចំពោះការប្រឡងជ្រើសរើសបេក្ខជនជាសិស្ស និស្សិត ឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃនេះ គណៈកម្មការរៀបចំការប្រឡងរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ ផ្សព្វផ្សាយដល់ជនពិការដែលមានសមត្ថភាពគ្រប់គ្រាន់ មកចូលរួមប្រឡងឲ្យបានច្រើន ។

អាស្រ័យហេតុនេះ សូមឯកឧត្តម រៀបចំចាត់ចែងផ្សព្វផ្សាយជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបជាព័ត៌មាន ។

សូមឯកឧត្តមទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh